យើងទាំងអស់គ្នាសច្ចា

# អនុសញ្ញាអង្គការសហប្រជាជាតស្ដីពីសិទ្ធិកុមារ

កំណែភាសាខ្មែរសម្រាប់កុមារ

**UN Convention on the Rights of the Child(Child Friendly Version) Cambodian(Khmer)**

**유엔아동권리협약 아동버전 캄보디아어판(크메르어)**



Ministry of Health and Welfare

National Center for the Rights of the Child

# អនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ

អនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ គឺជាការសច្ចាដែលយើងទាំងអស់គ្នាត្រូវគោរពតាមក្នុងគោលបំណងដើម្បីការលូតលាស់ប្រកបដោយសុខភាពល្អ និងសុវត្ថិភាពសម្រាប់កុមារ។

អនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី 20 ខែវិច្ឆិកាឆ្នាំ 1989 ហើយសាធារណរដ្ឋកូរ៉េបានសន្យាចូលរួមនៅឆ្នាំ 1991 ។

ព័ត៌មានលម្អិតសំខាន់ៗរបស់អនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ មានគោលការណ៍ទូទៅចំនួន 4 ។

### គ្មានការរើសអើង

កុមារទាំងអស់គួរតែទទួលបានសិទ្ធិស្មើគ្នា។

### គតផលប្រយោជន៍កុមារជាធំ

គ្រប់បញ្ហាទាំងអស់ដែលមានឥទ្ធិពលដល់កុមារ ការសម្រេចចិត្តត្រូវធ្វើឡើងដោយគិតផលប្រយោជន៍កុមារជាអាទិភាព។

### សិទ្ធិរស់រានមានជីវិត និងការអភិវឌ្ឍន៍

ត្រូវផ្ដល់ការការពារ និងការគាំទ្រដល់កុមារដើម្បីឱ្យពួកគេរស់នៅដោយសុវត្ថិភាព និងមានសុខភាពល្អ។

### គោរពទស្សនៈរបស់កុមារ

កុមារគួរអាចបញ្ចេញមតិផ្ទាល់ខ្លួនលើគ្រប់បញ្ហាដែលប៉ះពាល់ដល់កុមារ ហើយមតិរបស់ពួកគេគួរត្រូវបានទទួលគោរព។



# អនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ

**កំណែភាសាខ្មែរសម្រាប់កុមារ**

ប្រទេសជាច្រើនជុំវិញពិភពលោកបានចូលរួមក្នុងសន្ធិសញ្ញាដ៏សំខាន់មួយ ហៅថា 'អនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ'។ និងសច្ចាការពារសិទ្ធិកុមារ។

អនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ ផ្ដល់ចម្លើយចំពោះសំណួរផ្សេងៗដូចជា
'តើកុមារជានរណា?'
'តើកុមារមានសិទ្ធិអ្វីខ្លះ?'
និង
'តើរដ្ឋមានទំនួលខុសត្រូវអ្វីខ្លះ?'

សិទ្ធិទាំងអស់របស់កុមារមានទំនាក់ទំនងគ្នាទៅវិញទៅមក ហើយមានសារៈសំខាន់ដូចគ្នា ហើយមិនអាចត្រូវបានហូតពីកុមារឡើយ



1.
កុមារគឺជាមនុស្សដែល
មានអាយុក្រោម 18 ឆ្នាំ។

2.
កុមារគ្រប់រូបមានសិទ្ធិទាំងអស់នេះ
មិនថាពួកគេជានរណា រស់នៅទីណា
និយាយភាសាអ្វី ប្រកាន់សាសនាអ្វី
គិតបែបណា រូបរាងបែបណា ទោះបីពួក
គេជាក្មេងប្រុសឬក្មេងស្រី ទោះបី
ពួកគេពិការ ទោះបីពួកគេជាអ្នក
មានឬអ្នកក្រ ហើយមិនថាឪពុកម្តាយឬ
គ្រួសាររបស់ពួកគេជានរណា ឬ
មិនថាឪពុកម្តាយឬគ្រួសាររបស់
ពួកគេជឿលើអ្វីឬធ្វើអ្វីនោះទេ។
គ្មានកុមារណាម្នាក់គួរត្រូវបានគេប្រព្រឹត្តទៅ
លើ ដោយអយុត្តិធម៌ ទោះក្នុងហេតុផល
ណាក៏ដោយ។

3.
នៅពេលដែលមនុស្សពេញវ័យធ្វើការ
សម្រេចចិត្ត ពួកគេគួរតែគិតអំពីរបៀបដែល
ការសម្រេចចិត្តរបស់ពួក គេនឹងមានឥទ្ធិពល
ដល់កុមារ។ មនុស្សពេញវ័យទាំងអ ស់
គួរតែធ្វើអ្វីដែលគិតពីផលប្រយោជន៍របស់
កុមារជាធំ។ រដ្ឋាភិបាលគួរតែធានាឱ្យ
បានថាកុមារត្រូវបានការពារ និងមើលថែ
ដោយឪពុកម្តាយរបស់ពួកគេ ឬដោយមនុស្ស
ផ្សេងទៀត នៅពេលដែលវាចាំបាច់
។ រដ្ឋាភិបាលគួរតែធានាឱ្យបានថាមនុស្ស
និងទីកន្លែងដែលទទួលខុសត្រូវក្នុងការមើល
ថែទាំកុមារកំពុងបំពេញការងារបានល្អ។

4.
រដ្ឋាភិបាលត្រូវតែព្យាយាមឱ្យអស់ពីសមត្ថភាព
ដើម្បីធានាថាកុមារគ្រប់រូបនៅក្នុងប្រទេស
របស់ខ្លួនអាចទទួលបានសិទ្ធិទាំងអស់នៅ
ក្នុងអនុសញ្ញានេះ។

5.
រដ្ឋាភិបាលគួរតែអនុញ្ញាតឱ្យគ្រួសារ និង
សហគមន៍ណែនាំកូនៗរបស់ពួកគេ ដូច្នេះ
នៅពេលដែលពួកគេធំឡើង ពួកគេរៀនប្រើសិទ្ធិ
របស់ពួកគេតាមរបៀបដ៏ល្អបំផុត។

6.
កុមារគ្រប់រូបមានសិទ្ធិរស់រាន
មានជីវិត។ រដ្ឋាភិបាលត្រូវតែធ្វើឱ្យប្រាកដថា
កុមាររស់រានមានជីវិត និងអភិវឌ្ឍតាមរបៀប
ដែលល្អបំផុត។

**7.**
កុមារត្រូវតែទទួលបានការចុះឈ្មោះនៅពេលពួកគេកើត និងត្រូវបានផ្តល់ឈ្មោះដែលទទួលស្គាល់ជាផ្លូវការដោយរដ្ឋាភិបាល។ កុមារត្រូវតែមានសញ្ជាតិ។ នៅពេលណាដែលអាចធ្វើទៅបាន កុមារគួរស្គាល់ឪពុកម្តាយរបស់ពួកគេ ហើយត្រូវបានមើលថែដោយពួកគេ។

**8.**
កុមារមានសិទ្ធិចំពោះអត្តសញ្ញាណផ្ទាល់ខ្លួនរបស់ពួកគេ ដែលជាកំណត់ត្រាផ្លូវការនៃអត្តសញ្ញាណរបស់ពួកគេដែលរួមមានឈ្មោះ សញ្ជាតិ និងទំនាក់ទំនងគ្រួសារ។ គ្មាននរណាម្នាក់អាចដកហូតសិទ្ធិនេះចេញពីពួកគេបានឡើយ ប៉ុន្តែប្រសិនបើករណីនេះកើតឡើង រដ្ឋាភិបាលត្រូវតែជួយកុមារឱ្យទទួលបានអត្តសញ្ញាណរបស់ពួកគេមកវិញឱ្យបានឆាប់រហ័ស។

**9.**
កុមារមិនគួរត្រូវបានគេបំបែកចេញពីឪពុកម្តាយទេ លុះត្រាតែពួកគេមិនត្រូវបានឪពុកម្តាយមើលថែបានត្រឹមត្រូវ - ឧទាហរណ៍ ប្រសិនបើឪពុកម្តាយធ្វើបាបពួកគេ ឬមិនមើលថែកូនរបស់ខ្លួន។ កុមារដែលឪពុកម្តាយមិនរស់នៅជាមួយគ្នា គួរតែនៅបន្តរក្សាទំនាក់ទំនងជាមួយឪពុកម្តាយទាំងពីរដដែល លុះត្រាតែទំនាក់ទំនងនេះអាចបង្កគ្រោះថ្នាក់ដល់កុមារ។



**10.**
ប្រសិនបើកុមាររស់នៅក្នុងប្រទេសផ្សេងពីឪពុកម្តាយរបស់ពួកគេ រដ្ឋាភិបាលត្រូវតែអនុញ្ញាតឱ្យកុមារ និងឪពុកម្តាយធ្វើដំណើរដើម្បីឱ្យពួកគេអាចរក្សាទំនាក់ទំនង និងនៅជាមួយគ្នាបាន។

**11.**
រដ្ឋាភិបាលត្រូវតែបញ្ឈប់កុមារដែលត្រូវ" បានគេយកចេញពីប្រទេសនៅពេលដែលទង្វើនេះផ្ទុយនឹងច្បាប់ - ឧទាហរណ៍ ការត្រូវបានចាប់ពង្រត់ដោយនរណាម្នាក់ ឬត្រូវបានឃុំខ្លួននៅបរទេសដោយឪពុ កឬម្តាយ នៅពេលដែលឪពុកឬម្តាយម្ខាងទៀតមិនយល់ព្រម។

**12.**
កុមារមានសិទ្ធិបញ្ចេញមតិដោយសេរីលើបញ្ហាដែលប៉ះពាល់ដល់ពួកគេ។ មនុស្សពេញវ័យគួរតែស្តាប់ និងយកចិត្តទុកដាក់ចំពោះកុមារ។









**13.**

កុមារមានសិទ្ធិចែករំលែកដោយសេរីជាមួយអ្នកដទៃនូវអ្វីដែលពួកគេរៀន គិត និងមានអារម្មណ៍ តាមរយៈការនិយាយ គូរ សរសេរ ឬតាមមធ្យោបាយណាមួយផ្សេងទៀត លុះត្រាតែមធ្យោបាយនេះផ្តល់ទុក្ខទោសដល់អ្នកដទៃ។

**14.**

កុមារអាចជ្រើសរើសគំនិត ការគិត និងសាសនារបស់ខ្លួនបាន ប៉ុន្តែទង្វើនេះមិនគួរបញ្ឈប់មនុស្សផ្សេងទៀតពីការរីករាយនឹងសិទ្ធិរបស់ពួកគេនោះទេ។ ឪពុកម្តាយអាចណែនាំកូនដូច្នេះនៅពេលពួកគេធំឡើង ពួកគេរៀនប្រើសិទ្ធិនេះបានត្រឹមត្រូវ។

**15.**

កុមារអាចចូលរួម ឬបង្កើតក្រុម ឬអង្គការ ហើយពួកគេអាចជួបជាមួយអ្នកដទៃ ដរាបណាវាមិនប៉ះពាល់ដល់អ្នកដទៃ។

**16.**

កុមារគ្រប់រូបមានសិទ្ធិឯកជនភាព។ ច្បាប់ត្រូវតែការពារឯកជនភាពរបស់កុមារ គ្រួសារ ផ្ទះ ការទំនាក់ទំនង និងកេរ្តិ៍ឈ្មោះ (ឬឈ្មោះល្អ) ពីការវាយប្រហារណាមួយ។



**17.**

កុមារមានសិទ្ធិទទួលបានព័ត៌មានពីអ៊ីនធឺណិត វិទ្យុ ទូរទស្សន៍ កាសែត សៀវភៅ និងប្រភពផ្សេងៗទៀត។ មនុស្សពេញវ័យគួរតែប្រាកដថាព័ត៌មានដែលពួកគេកំពុងទទួលបានគឺមិនមានគ្រោះថ្នាក់ទេ។ រដ្ឋាភិបាលគួរតែលើកទឹកចិត្តប្រព័ន្ធផ្សព្វផ្សាយឱ្យចែករំលែកព័ត៌មានពីប្រភពផ្សេងៗគ្នាជាច្រើន ជាភាសាដែលកុមារទាំងអស់អាចយល់បាន។

**18.**

ឪពុកម្តាយគឺជាមនុស្សសំខាន់ដែលទទួលខុសត្រូវក្នុងការចិញ្ចឹមកូន។ នៅពេលដែលកុមារមិនមានឪពុកម្តាយទេ មនុស្សពេញវ័យម្នាក់ទៀតនឹងមានទំនួលខុសត្រូវនេះ ហើយពួកគេត្រូវបានគេហៅថា "អាណាព្យាបាល" ។ មាតាបិតា និងអាណាព្យាបាលគួរពិចារណាជានិច្ចនូវអ្វីដែលល្អបំផុតសម្រាប់កុមារ។ រដ្ឋាភិបាលគួរតែជួយពួកគេ។ នៅពេលណាដែលកូនមានឪពុកម្តាយទាំងសងខាង អ្នកទាំងពីរគួរតែទទួលខុសត្រូវក្នុងការចិញ្ចឹមកូន។

**19.**

រដ្ឋាភិបាលត្រូវតែការពារកុមារពីអំពើហិង្សា ការរំលោភបំពាន និងការមិនអើពើដោយនរណាម្នាក់ដែលមើលថែពួកគេ។

**20.**

កុមារគ្រប់រូបដែលមិនអាចទទួលបានការមើលថែបានដោយគ្រួសាររបស់ពួកគេ មានសិទ្ធិទទួលបានការថែទាំយ៉ាងត្រឹមត្រូវពីមនុស្សដែលគោរពសាសនា វប្បធម៌ ភាសា និងទិដ្ឋភាពផ្សេងទៀតនៃជីវិតរបស់កុមារ។

**21.**

នៅពេលកុមារត្រូវបានគេយកមកចិញ្ចឹម រឿងសំខាន់បំផុតគឺធ្វើអ្វីដែលល្អបំផុតសម្រាប់ពួកគេ។ ប្រសិនបើកុមារមិនអាចទទួលការមើលថែបានត្រឹមត្រូវក្នុងប្រទេសរបស់ពួកគេទេ នោះពួកគេអាចនឹងត្រូវយកទៅចិញ្ចឹមនៅប្រទេសផ្សេង។



22.
កុមារដែលផ្លាស់ពីប្រទេសកំណើតរបស់ពួកគេទៅប្រទេសមួយផ្សេងទៀតជាជនភៀសខ្លួន ព្រោះវាមិនមានសុវត្ថិភាពសម្រាប់ពួកគេក្នុងការស្នាក់នៅទីនោះ គួរតែទទួលបានជំនួយ និងការការពារ និងមានសិទ្ធិដូចគ្នានឹងកុមារដែលកើតនៅក្នុងប្រទេសនោះដែរ។

23.
កុមារពិការគ្រប់រូបដែលមានពិការភាព គួរតែរីករាយនឹងជីវិតដែលល្អបំផុតនៅក្នុងសង្គមតាមដែលអាចធ្វើបាន។ រដ្ឋាភិបាលគួរតែដកចេញនូវរាល់ឧបសគ្គ ដើម្បីឲ្យកុមារពិការមានឯករាជ្យភាព និងចូលរួមយ៉ាងសកម្មនៅក្នុងសហគមន៍បាន។

24.
កុមារមានសិទ្ធិទទួលបានការថែទាំសុខភាពល្អបំផុត ទឹកស្អាតសម្រាប់ផឹក អាហារដែលមានសុខភាពល្អ និងបរិស្ថានស្អាត និងមានសុវត្ថិភាពក្នុងការរស់នៅ។ មនុស្សពេញវ័យ និងកុមារគួរមានព័ត៌មានអំពីរបៀបរក្សាសុវត្ថិភាព និងសុខភាពល្អ។

25.
កុមារគ្រប់រូបដែលត្រូវបានគេដាក់នៅកន្លែងណាមួយឆ្ងាយពីផ្ទះសម្រាប់ការថែទាំ ការការពារ ឬសុខភាពរបស់ពួកគេ គួរតែទទួលបានការត្រួតពិនិត្យស្ថានភាពរបស់ពួកគេឱ្យបានទៀងទាត់ ដើម្បីមើលថាតើអ្វីៗមានភាពល្អប្រសើរឬអត់ ហើយប្រសិនបើនេះនៅតែជាកន្លែងល្អបំផុតសម្រាប់កុមារ។



**26.**
រដ្ឋាភិបាលគួរតែផ្តល់ប្រាក់ ឬជំនួយផ្សេងទៀតដើម្បីជួយកុមារពីគ្រួសារក្រីក្រ។

**27.**
កុមារមានសិទ្ធិទទួលបានអាហារ សំលៀកបំពាក់ និងកន្លែងរស់នៅប្រកបដោយសុវត្ថិភាព ដូច្នេះពួកគេអាចអភិវឌ្ឍតាមរបៀបដែលល្អបំផុត។ រដ្ឋាភិបាលគួរតែជួយគ្រួសារ និងកុមារដែលមិនមានលទ្ធភាពបែបនេះ។

**28.**
កុមារគ្រប់រូបមានសិទ្ធិទទួលបានការអប់រំ។ ការអប់រំបឋមសិក្សាគួរតែឥតគិតថ្លៃ។ ការអប់រំមធ្យមសិក្សា និងឧត្តមសិក្សាគួរតែមានសម្រាប់កុមារគ្រប់រូប។ កុមារគួរតែត្រូវបានលើកទឹកចិត្តឱ្យទៅសាលារៀនដល់កម្រិតខ្ពស់បំផុតដែលអាចធ្វើទៅបាន។ វិន័យក្នុងសាលាគួរគោរពសិទ្ធិកុមារ និងមិនត្រូវប្រើអំពើហិង្សាឡើយ។

**29.**
ការអប់រំរបស់កុមារគួរតែជួយពួកគេអភិវឌ្ឍបុគ្គលិកលក្ខណៈ ទេពកោសល្យ និងសមត្ថភាពរបស់ពួកគេយ៉ាងពេញលេញ។ វាគួរតែបង្រៀនពួកគេឱ្យយល់ពីសិទ្ធិផ្ទាល់ខ្លួនរបស់ពួកគេ និងគោរពសិទ្ធិ វប្បធម៌ និងភាពខុសគ្នារបស់អ្នកដទៃ។ វាគួរតែជួយពួកគេឱ្យរស់នៅដោយសន្តិភាព និងការពារបរិស្ថាន។

**30.**
កុមារមានសិទ្ធិប្រើប្រាស់ភាសា វប្បធម៌ និងសាសនារបស់ពួកគេផ្ទាល់ បើទោះបីជាទាំងនេះមិនត្រូវបានចែករំលែកដោយមនុស្សភាគច្រើននៅក្នុងប្រទេសដែលពួកគេរស់នៅក៏ដោយ។



**31.**
កុមារគ្រប់រូបមានសិទ្ធិសម្រាក
សម្រាកលំហែ និងលេង និងចូលរួម
ក្នុងសកម្មភាពវប្បធម៌
និងច្នៃប្រឌិត។

**32.**
កុមារមានសិទ្ធិទទួលបានការការពារ
ពីការធ្វើការងារដែលមានគ្រោះថ្នាក់
ឬអាក្រក់សម្រាប់ការអប់រំ សុខភាព
ឬការអភិវឌ្ឍរបស់ពួកគេ។
ប្រសិនបើកុមារធ្វើការ
ពួកគេមានសិទ្ធិទទួលបានសុវត្ថិភាព
និងទទួលបានប្រាក់ខែសមរម្យ។

**33.**
រដ្ឋាភិបាលត្រូវតែការពារ
កុមារពីការប្រើ
ផលិត ដាក់តាមខ្លួន ឬលក់ថ្នាំញៀន
ដែលបង្កគ្រោះថ្នាក់។

**34.**
រដ្ឋាភិបាលគួរតែការពារកុមារពីការ
កេងប្រវ័ញ្ចផ្លូវភេទ
(ត្រូវបានគេទាញយកផលប្រយោជន៍)
និងការរំលោភបំពានផ្លូវភេទ
រួមទាំងដោយមនុស្សបង្ខំកុមារ
ឱ្យរួមភេទដើម្បីលុយ ឬបង្កើតរូបភាពផ្លូវភេទ
ឬខ្សែភាពយន្តរបស់ពួកគេ។

**35.**
រដ្ឋាភិបាលត្រូវតែធានាឱ្យបានថា
កុមារមិនត្រូវបានចាប់ពង្រត់ ឬលក់
ឬនាំទៅប្រទេសផ្សេងទៀត
ឬកន្លែងដែលត្រូវបានគេកេងប្រវ័ញ្ចឡើយ
(ទាញយកផលប្រយោជន៍)។



**36.**

កុមារមានសិទ្ធិទទួលបានការការពារពីការកេងប្រវ័ញ្ចគ្រប់ប្រភេទផ្សេងទៀត (ត្រូវបានទាញយកប្រយោជន៍) តាមមធ្យោបាយណាក៏ដោយ ទោះបីជាករណីទាំងនេះមិនត្រូវបានលើកឡើងជាពិសេសនៅក្នុងអនុសញ្ញានេះក៏ដោយ។

**37.**

កុមារដែលត្រូវបានចោទប្រកាន់ថាបំពានច្បាប់ មិនគួរត្រូវបានសម្លាប់ ធ្វើទារុណកម្ម ប្រព្រឹត្តយ៉ាងឃោរឃៅ ដាក់គុកជារៀងរហូត ឬដាក់គុកជាមួយមនុស្សធំឡើយ។ ពន្ធនាគារគួរតែជាជម្រើសចុងក្រោយ ហើយសម្រាប់តែរយៈពេលខ្លីបំផុតប៉ុណ្ណោះ។ កុមារនៅក្នុងពន្ធនាគារគួរតែមានជំនួយផ្នែកច្បាប់ និងអាចរក្សាទំនាក់ទំនងជាមួយគ្រួសាររបស់ពួកគេបាន។

**38.**

កុមារមានសិទ្ធិទទួលបានការការពារក្នុងពេលមានសង្គ្រាម។ គ្មានក្មេងអាយុក្រោម 15 ឆ្នាំអាចចូលបម្រើកងទ័ព ឬចូលរួមក្នុងសង្គ្រាមបានទេ។

**39.**

កុមារមានសិទ្ធិទទួលបានជំនួយ ប្រសិនបើពួកគេរងការឈឺចាប់ ត្រូវបានគេមិនអើពើ ត្រូវបានគេប្រព្រឹត្តិចំពោះមិនល្អ ឬរងផលប៉ះពាល់ដោយសង្គ្រាម ដូច្នេះពួកគេអាចទទួលបានសុខភាព និងសេចក្តីថ្លៃថ្នូររបស់ពួកគេមកវិញ។

**40.**
កុមារដែលត្រូវបានចោទប្រកាន់ពីបទបំពានច្បាប់ មានសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ និងការប្រព្រឹត្តិចំពោះដោយយុត្តិធម៌។ គួរតែមានដំណោះស្រាយជាច្រើនដើម្បីជួយកុមារទាំងនេះឱ្យក្លាយជាសមាជិកល្អនៃសហគមន៍របស់ពួកគេ។ ពន្ធនាគារគួរតែជាជម្រើសចុងក្រោយប៉ុណ្ណោះ។

**41.**
ប្រសិនបើច្បាប់នៃប្រទេសមួយការពារសិទ្ធិកុមារបានល្អជាងអនុសញ្ញានេះ នោះច្បាប់ទាំងនោះគួរតែត្រូវបានប្រើប្រាស់។



**42.**
រដ្ឋាភិបាលគួរតែប្រាប់កុមារ និងមនុស្សពេញវ័យយ៉ាងសកម្មអំពីអនុសញ្ញានេះ ដើម្បីឱ្យមនុស្សគ្រប់គ្នាដឹងអំពីសិទ្ធិរបស់កុមារ។

**43.**
មាត្រាទាំងនេះពន្យល់ពីរបៀបដែលរដ្ឋាភិបាល អង្គការសហប្រជាជាតិ (រួមទាំងគណៈកម្មាធិការសិទ្ធិកុមារ និងអង្គការយូនីសេហ្វ) និងអង្គការផ្សេងទៀតធ្វើការដើម្បីធ្វើឱ្យប្រាកដថាកុមារទាំងអស់ទទួលបានសិទ្ធិទាំងអស់របស់ពួកគេ។

គណៈកម្មាធិការសិទ្ធិកុមារគោរពយ៉ាងឱឡារិកចំពោះឯកសារនេះ។

មជ្ឈមណ្ឌលជាតិសម្រាប់សិទ្ធិកុមារ បានបោះពុម្ពផ្សាយសៀវភៅថ្មីមួយជាភាសាខ្មែរ ដោយ បកប្រែពីកំណែនៃភាសាកូរ៉េរបស់កុមារអំពីអនុសញ្ញាអង្គការសហប្រជាជាតិស្តី ពីសិទ្ធិកុមារ ដែល រៀបចំឡើងវិញដោយ មជ្ឈមណ្ឌលជាតិសម្រាប់សិទ្ធិកុមារ ក្នុងគោលបំណងបំពេញកាតព្វកិច្ចរបស់ខ្លួនដើម្បីគាំទ្រដល់ការអនុវត្តរបស់ អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ សម្រាប់គ្រួសារពហុវប្បធម៌ដែល រស់នៅក្នុងប្រទេសកូរ៉េ ដើម្បីរំលឹកដល់ទិវាសិទ្ធិកុមារពិភពលោក នៅឆ្នាំ 2023 ។

*គណៈកម្មាធិការសិទ្ធិកុមារ បោះពុម្ពកំណែនៃសៀវភៅរបស់កុមារនៃអនុសញ្ញា អង្គការសហប្រជាជាតិស្តី ពីសិទ្ធិកុមារ និងណែនាំប្រើប្រាស់ឱ្យបានពេញលេញតាមរយៈ ការបកប្រែជាភាសាផ្សេងៗនៅក្នុងប្រទេស នីមួយៗ។*



## កំណែរបស់កុមារនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ បោះពុម្ពជាភាសាខ្មែរ

**កាលបរិច្ឆេទបោះពុម្ពផ្សាយ៖ ខែវិច្ឆិកា ឆ្នាំ** 2023
**បោះពុម្ពដោយ៖ មជ្ឈមណ្ឌលជាតិដើម្បីសិទ្ធិកុមារ**
**អ្នកបោះពុម្ពផ្សាយ៖ ឈុង លីក ជុង**
**អាសយដ្ឋាន៖ ជាន់ទី** 6 **និង** 7, **ថោវ៉ ជី**, 71 **សាំប៉ុងរ៉ូ**, **ជុងណូគុ**, **ទីក្រុងសេអ៊ូល**
**ទូរសព្ទ៖** 02-6454-8500
**គេហទំព័រផ្លូវការ៖** www.ncrc.or.kr
**រូបភាព៖ លី មីយ៉ុង ហ្វាន**

※ **ការបោះពុម្ពដោយគ្មានការអនុញ្ញាត និងការចម្លងខ្លឹមសារនេះដោយគ្មានការយល់ព្រមជាមុន នឹងត្រូវហាមឃាត់យ៉ាងតឹងរ៉ឹង។**



## យើងទាំងអស់គ្នាសច្ចា

កំណែរបស់កុមារនៃអនុសញ្ញាអង្គការសហប្រជាជាតស្តីពីសិទ្ធិកុមារ
បោះពុម្ពជាភាសាកូរ៉េ

កំណែរបស់កុមារនៃអនុសញ្ញាអង្គការសហប្រជាជាតស្តីពីសិទ្ធិកុមារ
បោះពុម្ពជាភាសាខ្មែរ